សុន្ទរកថារបស់ **លោក ហ៊ីហ្គឺជី យ៉ូស៊ីហ៊ីរ៉ូ**

ឧបទូត/អនុប្រធានបេសកកម្មទូត ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីសម្ពោធអគារបណ្តុះបណ្តាលនៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម

១៦ ធ្នូ ២០១៣

**សូមគោរព ឯកឧត្តម តែ គុយស៊ាង រដ្ឋលេខាធិការក្រសួងសុខាភិបាល!**

**សូមគោរព លោកជំទាវ ស៊ុី វណ្ណថា អភិបាលរងខេត្តខេត្តកំពង់ចាម!**

**សូមគោរព លោកវេជ្ជបណ្ឌិត គីមសួរ ភិរុណ ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ចាម!**

**សូមគោរព លោកវេជ្ជបណ្ឌិត មាស ជា ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម!**

**សូមគោរព អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចូលរួមក្នុង ពិធីសម្ពោធ ដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវអគារបណ្តុះបណ្តាលថ្មីក្នុងមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាមនេះជាមួយតំណាងដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាប្រជាជនខេត្តកំពង់ចាម។

ខ្ញុំក៏មានសេចក្តីសោមរីករាយជាពិសេសផងដែរដែលពិធីនេះត្រូវបានប្រារព្ធឡើងក្នុងឱកាសដ៏ពិសេសនៃឆ្នាំ២០១៣ដែលជាឆ្នាំខួបអនុស្សាវរីយ៍ទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

អគារបណ្តុះបណ្តាល និងស្នាក់នៅដែលជាអំណោយរបស់រដ្ឋាភិបាលជប៉ុននេះ នឹងអនុញ្ញាតិឲ្យមន្ទីរពេទ្យអាចរៀបចំវគ្គបណ្តុះបណ្តាលយ៉ាងមានប្រសិទ្ធភាពសម្រាប់បុគ្គលិកនិងនិស្សិតពេទ្យនៅក្នុងទីតាំងមន្ទីរពេទ្យផ្ទាល់។

តាមដែលខ្ញុំបានដឹង មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាមបាន និង កំពុងផ្តល់សេវាកម្មល្អបំផុត នៅក្នុងខេត្ត ហើយយើងសង្ឃឹមថាអគារបណ្តុះបណ្តាលថ្មីនេះនឹងក្លាយជាមជ្ឈមណ្ឌលបណ្តុះបណ្តាលសេវាសុខាភិបាលមួយនៅក្នុងខេត្តដែលនឹងរួមចំណែកដល់ការលើកស្ទួយវិស័យសុខាភិបាលជារួមនៅក្នុងខេត្តទាំងមូល។

ការកែលម្អសេវាសុខាភិបាលសម្រាប់ប្រជាជនកម្ពុជាទាំងអស់ គឺជាវិស័យអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា។"យុទ្ធសាស្ត្រចតុកោណ"ដែលដាក់ចេញដោយរាជរដ្ឋាភិបាលក៏បានរួមបញ្ចូល"ការលើកស្ទួយវិស័យសុខាភិបាល និងអាហារូបត្ថម្ភ" នៅក្នុងមុំមួយដែលផ្តោតសំខាន់ទៅលើការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្សផងដែរ។ តាមយុទ្ធសាស្ត្រនេះ យន្តការជាក់លាក់ដូចជាការបង្កើនការទទួលបានសេវាសុខាភិបាលតាមរយៈការពង្រីកទីតាំងផ្តល់សេវា និងការបង្កើនគុណភាពនៃសេវាសុខាភិបាលក៏ត្រូវបានអនុវត្តផងដែរ។ ឆ្លើយតបទៅនឹងគោលការណ៍នៃយុទ្ធសាស្ត្រនេះ ក៏ដូចជាអនុឡោមតាមគោលការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុនសម្រាប់កម្ពុជា រដ្ឋាភិបាលជប៉ុនបានសម្រេចផ្តល់កិច្ចសហប្រតិបត្តិកាសម្រាប់គម្រោងនេះជូនដល់មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម ។

ជាការពិតណាស់ រដ្ឋាភិបាលជប៉ុនបាន និងកំពុងបន្តឧបត្ថម្ភគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល ការផ្តល់សម្ភារៈបរិក្ខារពេទ្យ និងការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល និងបុគ្គលិកបច្ចេកទេសទាំងនៅរាជធានីភ្នំពេញ និងនៅតាមតំបន់ជនបទ។

សារៈសំខាន់នៃកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរក្នុងវិស័យសុខាភិបាលត្រូវបានបញ្ជាក់អះអាងឡើងវិញនៅក្នុងជំនួបជាច្រើន រួមទាំងជំនួបថ្នាក់កំពូលលើកចុងក្រោយនេះផងដែរ។ ក្នុងឱកាសនៃដំណើរទស្សនៈកិច្ចផ្លូវការរបស់នាយករដ្ឋមន្ត្រីជប៉ុននៅប្រទេសកម្ពុជាកាលពី ថ្ងៃទី១៦ ខែវិច្ឆិកាកន្លងមកនេះ លោកស៊ីនហ្សូ អាបេ បានជួបពិភាក្សាជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ហើយថ្នាក់ដឹកនាំទាំងពីរក៏បានឯកភាពគ្នាដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីនៅក្នុងវិស័យសុខាភិបាលព្រមទាំងឈានដល់ការចុះអនុស្សារណកិច្ចសហប្រតិបត្តិការដោយភាគីទាំងពីរថែមទៀតផង។

ក្នុងបរិបទនេះខ្ញុំជឿជាក់ថាអគារបណ្តុះបណ្តាលថ្មីនេះនឹងជួយពង្រីកការផ្តល់សេវាសុខាភិបាលហើយជាលទ្ធផលប្រជាពលរដ្ឋក្នុងខេត្តកំពង់ចាមនឹងរីករាយជាមួយការទទួលបានសេវាថែទាំសុខភាពកាន់តែប្រសើរ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាអគារបណ្តុះបណ្តាលថ្មីនេះនឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវ និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពដើម្បីទុកជានិមិត្តរូបមួយនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសយើងទាំងពីរ ហើយចំណងកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!